**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

**សំណុំរឿងលេខ:** ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**ភាគីដាក់ឯកសារ:** មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Queen's University Belfast

**ដាក់ជូន:** ការិយាល័យសហចៅក្រមស៊ើបអង្កេត

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦

**ចំនួនទំព័រ:** ៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:49
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

---

**ចម្លើយតបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Queen's University Belfast ទៅនឹង "ការអំពាវនាវឲ្យដាក់សារណាពីភាគីនៃសំណុំរឿង ០០៣ និង ០០៤ និងការអំពាវនាវឲ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី" របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក**

---

**<u>ផ្ញើជូន÷</u>**

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម
Michael G. KARNAVAS

**ការិយាល័យរដ្ឋបាល**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី÷**

ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉េន ពៅ
Philippe CANONNE

Laure DESFORGES
Ferdinand DJAMMEN NZEPA
Martine JACQUIN
Christine MARTINEAU
Bernabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES
Françoise GAUTRY
Isabelle DURAND
Nicole DUMAS

<u>**ដាក់ដោយ៖**</u>

មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Queen's University Belfast:

បណ្ឌិត Racheal Killean

បណ្ឌិត Luke Moffett

លោកស្រី Amanda Kramer

លោកស្រី Eithne Dowds

01298985



**សេចក្តីផ្តើម**

១. សារណានេះគឺជាចម្លើយតបទៅនឹង "ការអំពាវនាវឲ្យដាក់សារណាពីភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ និង ការអំពាវនាវឲ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី" ពីសំណាក់សហចៅក្រមស៊ើបអង្កេត ដោយស្វែងរកការបញ្ជាក់បំភ្លឺលើចម្ងល់ថាតើការវាយប្រហារដែលធ្វើឡើងដោយរដ្ឋ ឬអង្គការប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនផ្ទាល់ នៅក្រោមច្បាប់ ទំនៀមទម្លាប់អន្តរជាតិជាធរមាន ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ អាចជាការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល ដែរឬទេ ផ្អែកតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

២. ជំហររបស់យើងគឺថា ការវាយប្រហារនៅក្នុងស្ថានភាពបែបនេះ*អាច* ចាត់ទុកជាការវាយប្រហារអនុលោមតាមមាត្រា ៥។ យើងនឹងបង្ហាញពីចំណុចនេះ ជាសំខាន់តាមរយៈការពិនិត្យច្បាប់យុត្តិសាស្ត្រ បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ដើម្បីបង្ហាញឲ្យឃើញថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានសុពលភាព ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ យើងនឹងពិចារណាផងដែរពីការអភិវឌ្ឍថ្មីៗ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម័យទំនើប។ យើងមានទទ្បីករណ៍សំខាន់ចំនួនបី ដូចខាងក្រោម៖

១. ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានសុពលភាព ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានទទួលស្គាល់ថា ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនថាឡើយ ជនរងគ្រោះត្រូវបានចាត់ទុកជាជនស៊ីវិល ឬមិនមែននោះឡើយ

២. ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានសុពលភាព ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានទទួលស្គាល់ថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធអាចជាជនស៊ីវិល ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅពេលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តជាលក្ខណៈជាប្រព័ន្ធ ស្របតាមគោលនយោបាយរបស់រដ្ឋ ហើយ

៣. ច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅតែបន្តទទួលស្គាល់ថា ការវាយប្រហារប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធ អាចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

## ការធ្វើទុក្ខបុកម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៣. អនុលោមតាមធម្មនុញ្ញនូរ៉ែបឹក[1] និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[2] ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានកំណត់និយមន័យថាជា៖

> *... ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ឬអំពើអមនុស្សធម៌ផ្សេងៗទៀតដែលធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល* ***ឬ*** *ការធ្វើទុក្ខបុកម្នេញដោយមូលសារហេតុនយោបាយ ពូជសាសន៍ ឬសាសនា បើទោះបីជា ការប្រព្រឹត្តិនោះគឺជាការរំលោភលើច្បាប់ជាតិរបស់ប្រទេសដែលជាកន្លែងដែលបានប្រព្រឹត្ត ឬអត់ក៏ដោយ។*

៤. គេអាចមើលឃើញថា ប្រភេទទីពីរនេះពុំមានការលើកយោងទៅនឹងប្រជាជនស៊ីវិលទេ។ ភាពខុសគ្នានេះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងយុត្តាធិការក្រោយសង្គ្រាមលោកលើកពីរ ដែលបានកំណត់ប្រភេទចំនួនពីរនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ (១) អំពើប្រឆាំងនឹងប្រជាជនស៊ីវិល និង (២)ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា។

៥. ទាក់ទងទៅនឹងមូលដ្ឋានទីពីរ ច្បាប់យុត្តិសាស្ត្រគាំទ្រដល់សេចក្តីសន្និដ្ឋានដែលថា នៅក្នុងស្ថានភាពដែលរដ្ឋមានការពាក់ព័ន្ធនឹងអំពើអមនុស្សធម៌ និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា គ្មានលក្ខខណ្ឌតម្រូវដែលថា ជនរងគ្រោះត្រូវតែជាជនស៊ីវិលនោះទេ[3]។ ដូចដែលបានបញ្ជាក់ក្នុងសេចក្តីសម្រេចរបស់តុលាការកំពូលបារាំង ក្នុងរឿងក្តី *Barbie*៖ *វាគឺជាគោលបំណងនៃជនល្មើសក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ហើយវាមិនមែនជាគុណភាព ឬកត្តាជំរុញរបស់ជនរងគ្រោះទេ ដែលកំណត់លក្ខណៈនៃការធ្វើទុក្ខបុកម្នេញដែលបានប្រព្រឹត្ត...* ***ទាំងកត្តាជំរុញ***

---

[1] *អង្គការសហប្រជាជាតិ ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ, ឧបសម្ព័ន្ធភ្ជាប់នឹងកិច្ចព្រមព្រៀងសម្រាប់ការកាត់ទោស និងការផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗតាមលក្ខខណ្ឌអឺរ៉ុប* ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥, មាត្រា ៦(គ)។

[2] *ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង, ការផ្តន្ទាទោសជនមានទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងប្រឆាំងនឹងមនុស្សជាតិ,* ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥, មាត្រា II។

[3] *សំណុំរឿងលេខ ៣៥ (សវនាការអង្គជំនុំជម្រះ៖ សវនាការលើសំណុំរឿង Josef Altstötter និងអ្នកផ្សេងទៀត)* UNWCC, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧; នៅក្នុង *re Pilz. Holland* តុលាការទីក្រុងឡាអេ (អង្គជំនុំជម្រះព្រហ្មទណ្ឌពិសេស) ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៤៩; តុលាការពិសេសនៃតុលាការកំពូលព្រហ្មទណ្ឌ, ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ១៩៥០។

***របស់ជនរងគ្រោះ និងការចាត់ចំណាត់ថ្នាក់ពួកគេជាយុទ្ធជន មិនអាចដកចេញនូវចេតនាមានទោស*** *ដែលនាំទៅរកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវតែទទួលការកាត់ទោស... ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមទាំងអំពើអមនុស្សធម៌ផ្សេងៗ និងការធ្វើទុក្ខបុកម្នេញដែលប្រព្រឹត្តជាប្រព័ន្ធប្រឆាំងនឹងប្រជាជនដែលស្ថិតក្នុងជាតិសាសន៍ជាក់លាក់មួយ ឬសហគមន៍សាសនា ក្នុងនាមរបស់រដ្ឋដែលកំពុងអនុវត្តគោលនយោបាយអនុត្តរភាពមនោគមវិជ្ជារបស់ខ្លួន... រួមទាំងអំពើអមនុស្សធម៌ផ្សេងៗ និង**ការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងបច្ចាមិត្តនៃគោលនយោបាយនេះ មិនថាឡើយថា ការប្រឆាំងនេះអាចមានទម្រង់បែបណាមួយនោះទេ***[4]។

ក្រោយមកទៀត ជំហរនេះទទួលបានការគាំទ្រ ពីសាលាឧទ្ធរណ៍ទីក្រុងប៉ារីសនៅក្នុងរឿងក្តី *Touvier* ដែលតុលាការសម្រេចថា៖

*ប្រជាជនជ្វីហ្វ និងសមាជិកនៃចលនាតស៊ូដែលទទួលរងការធ្វើទុក្ខបុកម្នេញជាប្រព័ន្ធ ក្នុងនាមរបស់រដ្ឋមួយដែលអនុវត្តគោលនយោបាយឧត្តមភាពមនោគមវិជ្ជាខ្ពស់បំផុត ដែលការធ្វើទុក្ខបុកម្នេញនោះត្រូវបានធ្វើឡើង ដោយសារតែមូលហេតុនៃសមាជិកភាពរបស់ពួកគេក្នុងសហគមន៍ពូជសាសន៍ ឬសាសនាមួយ ហើយការអនុវត្តគោលនយោបាយរដ្ឋត្រូវបានធ្វើឡើង ដោយសារតែមូលហេតុនៃការប្រឆាំងរបស់ពួកគេទៅនឹងគោលនយោបាយនោះ ក៏អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចគ្នា*[5]។

៦. ឧក្រិដ្ឋកម្មបែបនេះ អាចត្រូវបានប្រព្រឹត្តដោយរដ្ឋមួយប្រឆាំងនឹងជនជាតិរបស់ខ្លួនផ្ទាល់។ ឧទាហរណ៍នៅក្នុងរឿងក្តី *Josef Altstötter និងអ្នកផ្សេងទៀត* តុលាការបានកត់សម្គាល់ថា "អំពើរបស់អាល្លឺម៉ង់ប្រឆាំងនឹងជនជាតិអាល្លឺម៉ង់អាចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[6]។ ពិតណាស់ គេបានសង្កេតឃើញថា "ទស្សនទាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានបញ្ចូលជាសំខាន់ទាក់ទងនឹងការផ្តន្ទាទោសបទល្មើសដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងជនជាតិ ដែលរដ្ឋចាត់ទុកថាជាសត្រូវរបស់ខ្លួន ដូចជានៅក្នុងករណីរបស់ប្រជាជនជ្វីហ្វអាឡឺម៉ង់ គ្រីស្តបរិស័ទអាល្លឺម៉ង់ និងជនជាតិ

---

[4] Jean-Olivier Viout (១៩៩៩) "ការជំនុំជម្រះរឿងក្តី Klaus Barbie និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" សន្និសីទស្តីពីគោលនយោបាយ និងច្បាប់ Hofstra ៣: ១៥៥-១៦៦។

[5] រឿងក្តី *សាធារណរដ្ឋបារាំង តទល់នឹង Paul Touvier,* សាលាឧទ្ធរណ៍ទីក្រុងប៉ារីស ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩២, ៣៥២។

[6] រឿងក្តី *Josef Altstötter និងអ្នកផ្សេងទៀត*, កំណត់ចំណាំទី ៣។

អាល្លឺម៉ង់ផ្សេងទៀត ដែលបានរងគ្រោះដោយសារមូលហេតុពូជសាសន៍ សាសនា ឬជំហរនយោបាយរបស់ពួកគេ[7]។

៧. ការគាំដល់ការយកចិត្តទុកដាក់លើការធ្វើទុក្ខបុកម្នេញ ដោយមិនគិតពីស្ថានភាពរបស់ជនរងគ្រោះ បានមកពីសន្និសីទឆ្នាំ ១៩៤៧ ស្តីពីការដាក់បញ្ចូលគ្នានូវច្បាប់ព្រហ្មទណ្ឌ ដែលបានផ្តោតជាសំខាន់លើអត្ថិភាពនៃការធ្វើទុក្ខបុកម្នេញ។ សេចក្តីសម្រេចនៃសន្និសីទនេះ ដែលបានរៀបចំសេចក្តីព្រាងដោយ "អ្នកច្បាប់ល្អបំផុតនៅក្នុងពិភពលោក" មួយចំនួននោះ[8] បានស្នើឱ្យមាននិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានដកចេញនូវទស្សនទាននៃ "ជនស៊ីវិល" ហើយបានបញ្ជាក់ជំនួសមកវិញថា៖

*រាល់ការធ្វើមនុស្សឃាត ឬអំពើដែលអាចនាំដល់សេចក្តីស្លាប់ ដែលប្រព្រឹត្តក្នុងពេលមានសន្តិភាពក៏ដូចជាក្នុងពេលសង្គ្រាម ប្រឆាំងនឹងបុគ្គល ឬក្រុមនៃបុគ្គល ដោយសារតែពូជសាសន៍ សញ្ជាតិ សាសនា ឬមតិយោបល់របស់ពួកគេ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងត្រូវតែបានផ្តន្ទាទោសដូចគ្នានឹងការសម្លាប់មនុស្សដែរ[9]*។

៨. នៅក្នុងការអត្ថាធិប្បាយថ្មីៗរបស់គាត់ ស្តីពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ Cassese បានកត់សម្គាល់ថា ដោយសារ "គ្មានការសំដៅដល់ជនរងគ្រោះដែលអាចរងការធ្វើទុក្ខបុកម្នេញ ឬថា ដោយសារគ្មានការបញ្ជាក់ថា ការធ្វើទុក្ខបុកម្នេញបែបនេះគួរកំណត់គោលដៅលើ "ប្រជាជនស៊ីវិលណាមួយ" នោះ គេអាចសំដៅថា មិនត្រឹមតែក្រុមជនស៊ីវិលណាមួយទេ ប៉ុន្តែសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ក៏អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រភេទនេះផងដែរ"[10]។ គាត់បានសន្និដ្ឋានថា៖

---

[7] កំណត់សម្គាល់ស្តីពី*ការជំនុំជម្រះ* រឿងក្តី *Wilhelm Gerbsh*, តុលាការពិសេសនៅទីក្រុង Amsterdam, អង្គជំនុំជម្រះលើកដំបូង, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៤៨, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (វ៉ុល XIV) (Forward)។

[8] Joseph Y. Dautricourt (១៩៤៩-១៩៥០)។ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ការយល់ឃើញអឺរ៉ុបចំពោះទស្សនទាន និងអនាគតរបស់ខ្លួន" *ទិនានុប្បវត្តិនៃច្បាប់ព្រហ្មទណ្ឌ និងឧក្រិដ្ឋកម្មសាស្ត្រ* ៥០:១៧០។

[9] សេចក្តីសម្រេចនៃសន្និសីទលើកទី VIII សម្រាប់ការដាក់បញ្ចូលគ្នានៃច្បាប់ព្រហ្មទណ្ឌ, ទីក្រុងព្រុចសែល ថ្ងៃទី ១០ និងទី ១១ ខែ កក្កដា ឆ្នាំ ១៩៤៧។

[10] Antionio Cassese, *ច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ* (កំណែលើកទី ២) (Oxford University Press, ឆ្នាំ ២០០៨), ១១៨។

*ច្បាស់ណាស់ នៅពេលមានសន្តិភាព បុគ្គលិកយោធាក៏អាចក្លាយទៅជាកម្មវត្ថុនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ ដោយសារអំពើរបស់អាជ្ញាធរខ្លួន។ ដូចគ្នានេះដែរ នៅពេលមានអរិភាពប្រដាប់អាវុធ* ***លែងមានមូលហេតុសម្រាប់ការដកចេញនូវអ្នកផ្តល់សេវា មិនថាជាអ្នកមានសមត្ថភាពប្រយុទ្ធ ឬអត់ (អ្នករបួស អ្នកជំងឺ ឬអ្នកទោសសង្គ្រាម) នោះទេ*** *ពីការការពារប្រឆាំងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ជាសំខាន់ ការធ្វើទុក្ខបុកម្នេញ) មិនថា វាត្រូវបានប្រព្រឹត្តដោយអាជ្ញាធរផ្ទាល់របស់ពួកគេ ឬដោយកងកម្លាំងសម្ព័ន្ធមិត្ត ឬដោយសត្រូវ ឬអត់នោះទេ*[11] ។

៩. យើងទទួលស្គាល់ថា មាត្រា ៥ មិនមានបង្ហាញពីភាពខុសគ្នារវាងអំពើប្រឆាំងនឹងជនស៊ីវិល និងការធ្វើទុក្ខបុកម្នេញទេ។ ទោះយ៉ាងណា ការដាក់បញ្ចូលមាត្រាស្តីពី *"មូលហេតុជនជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"* រក្សាគោលដៅក្នុងការកាត់ទោសលើការធ្វើទុក្ខបុកម្នេញ ហើយដូច្នេះគួរតែត្រូវបានបកស្រាយ ដោយរួមបញ្ចូលទាំងអំពើអមនុស្សធម៌ដែលប្រព្រឹត្តប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ដោយសារតែមូលហេតុជនជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។

## យុទ្ធជនជា "ជនស៊ីវិល"

១០. ប្រភេទទីមួយនៃបទល្មើសក្រោមធម្មនុញ្ញនូរ៉ឹប៊ែក និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង៖ "អំពើប្រឆាំងនឹងប្រជាជនស៊ីវិល" ដំបូងមានគោលបំណងសំដៅលើប្រជាជនទូទៅ មិនមែនជាយុទ្ធជនទេ។ ទោះយ៉ាងណា បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ តុលាការមួយចំនួនបានចាប់ផ្តើមអនុម័តការបកស្រាយបែបសេរីនៃពាក្យ "ជនស៊ីវិល"[12] ដោយតុលាការផ្តោតការយកចិត្តទុកដាក់ជំនួសវិញ ថាតើឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តក្នុងលក្ខណៈជាប្រព័ន្ធមួយស្របតាមគោលនយោបាយរបស់រដ្ឋ ឬទេ។

១១. ឧទាហរណ៍ នៅក្នុងរឿងក្តី *R.* (*StS 19/48*)[13] តុលាការកំពូលនៃតំបន់ដែលកាន់កាប់ដោយអង់គ្លេសបានសម្រេចថា ការបរិហារមន្ត្រីគ្មានសក្តិក្នុងឯកសណ្ឋាន និងសមាជិកនៃបក្សណាស៊ី និង SA ពីបទប្រមាថថ្នាក់ដឹកនាំបក្ស អាចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដរាបណាការបរិហារនោះ

---

[11] *ដូចឯកសារខាងលើ* ទំព័រ ១២២។

[12] *ដូចឯកសារខាងលើ* ទំព័រ ១១៨ ដល់ ១១៩។

[13] *សំណុំរឿង R. (StS 19/48)*, តុលាការកំពូលសម្រាប់តំបន់ដែលកាន់កាប់ដោយអង់គ្លេស, *ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៤៨*។

អាចនឹងត្រូវបានបង្ហាញឲ្យឃើញថា គោលបំណងរបស់មន្ត្រីនោះគឺដើម្បីបញ្ជូនជនរងគ្រោះទៅដល់ "របនាសម្ព័ន្ធអំណាចដែលមិនអាចគ្រប់គ្រងរបស់បក្ស និងរដ្ឋ" ដោយដឹងថា ជាលទ្ធផល ជនរងគ្រោះទំនងជាត្រូវបានជាប់នៅក្នុងប្រព័ន្ធដែលធ្វើតាមទំនើងចិត្ត និងហិង្សា[14]។ ស្រដៀងគ្នានេះដែរ នៅក្នុងរឿងក្តី *P. និងអ្នកផ្សេងទៀត* សមាជិកប្រាំរូបនៃតុលាការសង្គ្រាមត្រូវបានរកឃើញថាមានទោសពីបទសមគំនិតក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសារតួនាទីរបស់ពួកគេក្នុងការសម្លាប់ទាហានជើងទឹកជនជាតិអាល្លឺម៉ង់បីនាក់ដែលបានព្យាយាមរត់គេច ពីប្រទេសដាណឺម៉ាក បន្ទាប់ពីមានការចុះចាញ់ដោយផ្នែករបស់ប្រទេសអាល្លឺម៉ង់។ តុលាការនេះបានកត់សម្គាល់ថា៖

*នរណាក៏ដោយដែលកត់សម្គាល់ពីបុគ្គលិកលក្ខណៈពិសេសនៃករណី និងថ្នាក់នៃករណីដែលបានរៀបរាប់នៅទីនោះ [មាត្រាទី II(១)(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង]* ***មិនអាចទាញសេចក្តីសន្និដ្ឋានដែលថា សកម្មភាពរវាងទាហានទាំងនោះមិនអាច ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ*** *។ [និយាយដោយត្រង់] ទង្វើហួសហេតុតែមួយគត់ និងដាច់តែឯងនឹងមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ ដោយអនុលោមតាមសញ្ញាណច្បាប់ពីឧក្រិដ្ឋកម្មបែបនេះ។ [ទោះយ៉ាងណា] វាត្រូវបានបង្ហាញរួចហើយថា សកម្មភាពចោទនោះអាចជាសកម្មភាពក្នុងប្រព័ន្ធព្រហ្មទណ្ឌ និងនិន្នាការព្រហ្មទណ្ឌនៃសម័យណាស៊ី[15]។*

នៅក្នុង*រឿងក្តី H.* តុលាការដដែលនោះបានសម្រេចថា ចៅក្រមម្នាក់ដែលបានកាត់ទោសប្រហារជីវិតមន្ត្រីកងទ័ពជើងទឹកអាឡឺម៉ង់ពីរនាក់ អាចនឹងត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងវិសាលភាពដែលថា សកម្មភាពរបស់គេបានធ្វើឡើងដោយចេតនាដោយផ្សារភ្ជាប់នឹងប្រព័ន្ធហិង្សា និងភ័យរន្ធត់បែបណាស៊ី[16]។ តុលាការកំពូលបារាំងបានអនុវត្តវិធីសាស្ត្រស្រដៀងគ្នាដែរ ចំពោះរឿងក្តី *Barbie* ដោយបានច្រានចោលការសម្រេចរបស់តុលាការថ្នាក់ក្រោមដែលថា Barbie មិនអាចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តប្រឆាំងនឹងសាស្ត្រាចារ្យ Gompel នោះទេ ព្រោះវា "មិនច្បាស់ទេ ថាតើសាស្ត្រាចារ្យ Gompel ត្រូវបាន

[14] *ដូចឯកសារខាងលើ* ទំព័រ ៤៧។

[15] រឿងក្តី *P. និងអ្នកផ្សេងទៀត,* ប្រទេសអាល្លឺម៉ង់, តុលាការកំពូលនៅតំបន់ដែលកាន់កាប់ដោយអង់គ្លេស ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៤៨, ២២៨។

[16] រឿងក្តី *H.* ប្រទេសអាល្លឺម៉ង់, តុលាការកំពូលក្នុងតំបន់ដែលកាន់កាប់ដោយអង់គ្លេស ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៤៩, ទំព័រ ២៣៣-២៣៤, ២៣៨, ២៤១ ដល់ ៤។

ចាប់ខ្លួនដោយសារតែគាត់ជាជនជាតិជ្វីហ្វ ឬដោយសារគាត់ជាសមាជិកនៃចលនាតស៊ូនោះ។ តុលាការនេះបានសម្រេចថា៖

*ដោយហេតុថា អ្វីដែលជាឧក្រិដ្ឋកម្មដែលមិនអាចដកចេញបានប្រឆាំងនឹងមនុស្សជាតិ ... [រួមបញ្ចូលទាំង]* ***អំពើអមនុស្សធម៌ និងការធ្វើទុក្ខបុកម្នេញ ក្នុងនាមរបស់រដ្ឋដែលអនុវត្តមនោគមវិជ្ជានយោបាយបែបអនុត្តរភាព ត្រូវបានប្រព្រឹត្តជាប្រព័ន្ធ ដែលមិនត្រឹមតែប្រឆាំងនឹងមនុស្ស ដោយសារពួកគេស្ថិតក្នុងក្រុមជាតិសាសន៍ ឬក្រុមសាសនាមួយនោះទេ ប៉ុន្តែថែមទាំង ប្រឆាំងនឹងសត្រូវនៃគោលនយោបាយ [រដ្ឋ] នេះផងដែរ*** *មិនថា ការប្រឆាំងរបស់ពួកគេក្នុងទម្រង់បែបណាក៏ដោយ ... ហើយខណៈពេលដែលទាំងចេតនាផ្លូវចិត្តរបស់ជនរងគ្រោះ* ***ទាំងលទ្ធភាពដែលថា ពួកគេគឺជាយុទ្ធជន*** *មិនអាចបដិសេធអត្ថិភាព ចំពោះភាគីចុងចោទនៃចេតនាផ្លូវចិត្តដែលគេទាមទារឲ្យមានសម្រាប់ការប្រព្រឹត្តិបទល្មើសដែលគេតាមរក សាលាដំបូងដែលចោទប្រកាន់បានយល់ខុសលើវិសាលភាព និងអត្ថន័យនៃច្បាប់*[17] ។

ដូច្នេះ ស្ថានភាពរបស់ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានសម្រេចម្តងហើយម្តងទៀតថាមិនមានការពាក់ព័ន្ធ នៅកន្លែងដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងក្នុងបរិបទនៃរដ្ឋដែលអនុវត្តមនោគមវិជ្ជានយោបាយបែបអនុត្តរភាព ដែលត្រូវបានអនុវត្តតាមរយៈប្រព័ន្ធទំនើងចិត្ត និងហិង្សា។ ក្នុងវិសាលភាពដែលថា ឧប្បត្តិហេតុបែបនោះនឹងបំពេញលក្ខខណ្ឌដ៏ទូលំទូលាយ និងជាប្រព័ន្ធនោះ មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អាចនឹងត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ដោយអនុញ្ញាតឲ្យសមាជិកនៃកងកម្លាំងប្រដាប់អាវុធក្លាយជាជនរងគ្រោះនៃការវាយប្រហារ សម្រាប់គោលបំណងនៃមាត្រានេះ។

### ពីជនស៊ីវិលទៅជា*អ្នកបាត់បង់សមត្ថភាពប្រយុទ្ធ*

១២. ខណៈពេលដែលពុំមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពីឆ្នាំ ១៩៧៥ ដើល់ឆ្នាំ ១៩៧៩ គេគួរតែកត់សម្គាល់ថា យុត្តាធិការជាបន្តបន្ទាប់មិនបានដកសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ចេញពីការដែលត្រូវចាត់ទុកថាជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។ ថ្វីបើតុលាការសម័យបច្ចុប្បន្នមិនបានបង្ហាញពីបញ្ហាជាក់លាក់ដែលត្រូវបានយក

---

[17] Leila Sadat Wexler (១៩៩៤-១៩៩៥)។ "ការបកប្រែគោលការណ៍នូវប៊ែកដោយតុលាការកំពូលព្រហ្មទណ្ឌបារាំង៖ ពី Touvier ទៅ Barbie និងត្រឡប់មកវិញ" *ទិនានុប្បវត្តិច្បាប់ឆ្លងដែនកូឡុំប៊ី*, ៣២:២៨៩ ដល់ ៣៨០, ៣៤២។

មកពិចារណាក្នុងការដាក់សារណានេះក្ដី ក៏ការណែនាំមួយចំនួនអាចត្រូវបានរកឃើញនៅក្នុងយុត្តាធិការរបស់តុលាការទាំងនោះលើបញ្ហាស្រដៀងគ្នានេះដែរ។

១៣. តុលាការឧក្រិដ្ឋកម្មអន្តរជាតិ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា បានបញ្ចេញការយល់ថា "ប្រជាជនដែលជាគោលដៅត្រូវតែមានលក្ខណៈជាជនស៊ីវិលភាគច្រើន។ វត្តមានរបស់ជនមិនមែនស៊ីវិលមួយចំនួនក្នុងចំណោមពួកគេ មិនបានផ្លាស់ប្ដូរលក្ខណៈនៃប្រជាជននោះឡើយ[18]។ ចំណុចនេះត្រូវបានអះអាងក្នុងរឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Germain Katanga* ដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានសម្រេចថា "បទល្មើសនេះអាចត្រូវបានបង្ហាញ បើទោះបីជាប្រតិបត្តិការយោធាបានដៅលើគោលបំណងយោធាស្របច្បាប់ដែរក៏ដោយ។ ទោះយ៉ាងណា វាជាការសំខាន់ក្នុងការបញ្ជាក់ថា កម្មវត្ថុចម្បងនៃការវាយប្រហារនោះគឺប្រជាជនស៊ីវិលជារួម ឬជនស៊ីវិលម្នាក់ៗ[19]។

១៤. ទោះជាយ៉ាងណា យុត្តាធិការពីតុលាការទាំងនេះមានភាពស៊ីសង្វាក់គ្នាក្នុងការបញ្ជាក់ថា "មិនមានតម្រូវការ ឬវាមិនមែនជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មជាមូលដ្ឋានគឺជា "ជនស៊ីវិល" ឡើយ[20]។ នៅក្នុងរឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Kupreškíc* តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានប្រកាន់ជំហរថា "អ្នកដែលបានចូលរួមយ៉ាងសកម្មនៅក្នុងចលនាតស៊ូមួយ អាចមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងនាមជាជនរង

---

[18] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Tadić* (IT-94-1-T), ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៧, កថាខណ្ឌ ៦៣៨; រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Blaškić* (IT-95-14-A) ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤, កថាខណ្ឌ ១១៤-១១៥; រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Kordić & Čerkez* (IT-95-14/2-A) ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤, កថាខណ្ឌ ៥០ និង ៩៧; រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Galić* (IT-98-29-A) ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦, កថាខណ្ឌ ១៣៦-១៣៧; រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Akayesu* (ICTR-96-4-T) ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨, កថាខណ្ឌ ៥៨២, លេខ ១៤៦; រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Jean-Pierre Bemba Gombo* (ICC-01/05 -01/08) ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦, កថាខណ្ឌ ១៥៣; រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Germain Katanga* (ICC-01/04-01/07) ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៤, កថាខណ្ឌ ៨០២។

[19] Katanga, ដូចឯកសារខាងលើ, ទំព័រ៨០២។

[20] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Mrkšić និង Šljivančanin* (IT-95-13/1-A) ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០០៩, កថាខណ្ឌ ៣២; រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃទៀត* (IT-05-88-A) ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥, កថាខណ្ឌ ៧៧៣; *Bemba*, លេខ ១៨ កថាខណ្ឌ ១៥៥។

គ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”[21] ហើយនៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Mrkšić និង Šljivančanin* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបដិសេធចំពោះការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនរងគ្រោះសំខាន់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែជាជនស៊ីវិល ដោយបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតលក្ខខណ្ឌតម្រូវបន្ថែមដោយភាន់ច្រឡំ[22]។ តាមពិត ច្បាប់យុត្តិសាស្ត្រថ្មីៗបង្ហាញថា សាលាក្តីទាំងនេះកំពុងធ្វើការបកស្រាយទូលំទូលាយនៃពាក្យ “ជនស៊ីវិល” ដែលរួមបញ្ចូលទាំង*អ្នកបាត់បង់សមត្ថភាពប្រយុទ្ធ។* នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា តុលាការបានសម្រេចថា ការពឹងផ្អែកលើភាពខុសគ្នារវាងអ្នកប្រយុទ្ធ និងជនស៊ីវិលដែលបានមកពីច្បាប់ស្តីពីមនុស្សធម៌អន្តរជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមនាំមកនូវការអនុវត្តមិនត្រឹមត្រូវនៃលក្ខណៈឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ឧទាហរណ៍ នៅក្នុងរឿងក្តីឃោផា ដែលកងរក្សាសន្តិភាព ១0 នាក់របស់ប្រទេសបែលហ្ស៊ិកត្រូវបានចាប់ខ្លួនដោយកងទ័ពប្រទេសរ៉្វាន់ដា ត្រូវវាយដំ និងសម្លាប់ វាមិនសំខាន់ទេថា មនុស្សម្នាក់ក្នុងចំណោមពួកគេបានទទួលអាវុធដើម្បីប្រើការពារខ្លួន មុនពេលដែលពួកគេត្រូវបានសម្លាប់ ដោយសារវាបានផ្លាស់ប្តូរ ស្ថានភាពងាយរងគ្រោះរបស់ពួកគេ ហើយការវាយប្រហារប្រឆាំងនឹងពួកគេបង្កើតបានជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[23]។ សំណួរថាតើពួកគេជាជនស៊ីវិល ឬយ៉ាងណានោះ គឺមិនសំខាន់ទេ ជំនួសមកវិញ ការផ្តោតការយកចិត្តទុកដាក់ ថាតើពួកគេអាចចាត់ចំណាត់ថ្នាក់ជាយុទ្ធជនបានឬយ៉ាង។

១៥. ដូច្នេះ គេអាចមើលឃើញថា សាលាក្តីនេះបានទទួលស្គាល់ថា ការសម្លឹងមើលភាពខុសគ្នារវាងយុទ្ធជន និងជនស៊ីវិល មិនបានសំដៅដល់រាល់*អ្នកបាត់បង់សមត្ថភាពប្រយុទ្ធ*ទេ។ នៅពេលនិយាយពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ *អ្នកបាត់បង់សមត្ថភាពប្រយុទ្ធ* (ជាឈ្មោះកាន់តែសមស្របនៃជនស៊ីវិល) បានចាប់យកប្រសើរជាងនូវភាពងាយរងគ្រោះ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែល*ជនបាត់បង់សមត្ថភាពប្រយុទ្ធ* ត្រូវបានសម្លាប់រង្គាល។ ដូច្នោះហើយ ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹង

---

[21] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kupreškíc* (IT-95-16-T) ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២000, កថាខណ្ឌ ៥៤៩។

[22] រឿងក្តី *Mrkšić និង Šljivančanin*, លេខ ១៨, កថាខណ្ឌ ៣៣។

[23] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Théoneste Bagosora និងអ្នកផ្សេងទៀត* (ICTR-98-41-T) ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២00៨ កថាខណ្ឌទី ២១៧៥ និងទី ២២៣៩, និង រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Augustin Ndindiliyimana, Augustin Bizimungu, François-Xavier Nzuwonemeye, Innocent Sagahutu* (ICTR-00-56-T) ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២0១១, កថាខណ្ឌ ២0៩៥ ដល់ ៩៦ និង ២១៤0។

01298994



មនុស្សជាតិមិនមែនជា "អង្គភាពរូបវន្តដ៏ធំដែលបង្រួបបង្រួមគ្នា" ទេ ប៉ុន្តែជាក្រុមនៃបុគ្គលដែលបានកំណត់ ដែលងាយរងគ្រោះពីការកំណត់គោលដៅ ជាផ្នែកមួយនៃផែនការ ឬគោលនយោបាយឲ្យមានការវាយប្រហារលើភាពសុចរិត និងសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនរបស់ពួកគេ[24]។

## សេចក្តីសន្និដ្ឋាន

១៦. ការដាក់សារណាខ្លីនេះបញ្ជាក់ថា ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទទួលស្គាល់ថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធអាចនឹងត្រូវបានចាត់ទុកថាទទួលរងគ្រោះដោយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងករណីដែលពួកគេបានទទួលរងនូវការធ្វើទុក្ខបុកម្នេញ ហើយក្នុងករណីដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្ត ក្នុងនាមនៃគោលនយោបាយរបស់រដ្ឋដ៏ទូលំទូលាយ តាមរយៈរចនាសម្ព័ន្ធនៃអំពើហិង្សា។ ឧក្រិដ្ឋកម្មបែបនេះអាចនឹងត្រូវបានប្រព្រឹត្តដោយរដ្ឋប្រឆាំងនឹងជនជាតិរបស់ខ្លួនផ្ទាល់។ ខណៈដែលច្បាប់យុត្តិសាស្ត្រថ្មីៗបានចាត់ទុកថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែជាជនស៊ីវិលភាគច្រើន ច្បាប់នេះមិនបានដកចេញនូវសមាជិកនៃកងកម្លាំងប្រដាប់អាវុធថាមិនអាចត្រូវបានចាត់ទុកជាជនរងគ្រោះទេ ហើយ ជាការពិតតុលាការចាប់ផ្តើមបង្ហាញនូវការបកស្រាយទូលំទូលាយនៃពាក្យថា "ជនស៊ីវិល"។

១៧. M. Cherif Bassiouni បានកំណត់អត្តសញ្ញាណច្បាប់សម័យទំនើបស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថាមានលក្ខណៈពិសេសពីរយ៉ាង៖

*(១) ឧក្រិដ្ឋកម្មទាំងនេះយោងទៅអំពើហិង្សាជាក់លាក់ប្រឆាំងនឹងមនុស្ស ដោយមិនគិតថាតើបុគ្គលនោះជាជនជាតិមួយ ឬមិនមែននោះទេ និងដោយមិនចំពោះថាអំពើទាំងនេះត្រូវបានប្រព្រឹត្តក្នុងពេលមានសង្គ្រាម ឬក្នុងពេលសន្តិភាពទេ និង (២) អំពើទាំងនេះត្រូវតែជាលទ្ធផលនៃការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងក្រុមមនុស្សដែលអាចកំណត់អត្តសញ្ញាណបាន ដោយមិនគិតថា ក្រុមនោះរួមផ្សំដោយនរណា ឬគោលបំណងការធ្វើទុក្ខបុកម្នេញ ឬយ៉ាងណានោះទេ។ គោលនយោបាយបែបនេះក៏*

---

[24] David Luban (២០០៤)។ "ទ្រឹស្តីនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" *ទិនានុប្បវត្តិយ៉េលនៃច្បាប់អន្តរជាតិ* ២៩៖១, ៨៥ ដល់ ១៦៧, ៩៧។

*អាចនឹងត្រូវបានបង្ហាញដោយអំពើ "យ៉ាងរីករាលដាល ឬជាប្រព័ន្ធ" របស់ជនល្មើស ដែលបង្ក ក្នុងពេលប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់នានាដែលមាននៅក្នុងនិយមន័យនេះ*[25]។

១៨. ដូច្នេះ គេអាចមើលឃើញថា ច្បាប់ទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនបានច្រានចោលការវាយប្រហារប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធថាមិនមែនជាឧក្រិដ្ឋកម្មនោះទេ។ ការកំណត់ជាបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានបង្កើតឡើង ដើម្បីការពារបុគ្គលដែលអាចទទួលរងការរំលោភបំពានពីអ្នកកាន់អំណាច[26]។ ក្នុងន័យកាន់តែជានិមិត្តរូបនោះ ឧក្រិដ្ឋកម្មទាំងនេះដាក់ទោសចំពោះការមិនយកចិត្តទុកដាក់ធ្ងន់ធ្ងរចំពោះស្មារតី ជីវិត ភាពសុចរិត និងសេចក្តីថ្លៃថ្នូរ ដែលប៉ះពាល់យ៉ាងខ្លាំងលើមនុស្សជាតិ[27]។ ការបកស្រាយមាត្រា ៥ ដែលអនុញ្ញាតឲ្យការវាយប្រហារដោយរដ្ឋ ឬអង្គការប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់ខ្លួន គឺការវាយប្រហារ ដែលធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល ស្របនឹងគោលបំណងរួមនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់មនុស្សជាតិអន្តរជាតិ ដើម្បីលើកកម្ពស់នូវវិសាលភាពទូលំទូលាយនៃការការពារតម្លៃជាមូលដ្ឋាននៃសេចក្តីថ្លៃថ្នូររបស់មនុស្ស ដោយមិនគិតពីស្ថានភាពផ្នែកច្បាប់នៃអ្នកដែលមានសិទ្ធិទទួលបានការការពារ[28]។ ដូច្នេះ ភាពទូលំទូលាយនៃលក្ខខណ្ឌតម្រូវជា "ប្រជាជនស៊ីវិល" បានប្រែទៅជាកម្រិតកាន់តែទាបក្នុងការបញ្ជាក់ នៅពេលបកស្រាយប្រឆាំងនឹងធាតុផ្សំផ្សេងទៀតនៅក្នុង*លក្ខខណ្ឌរួម* នៃឧក្រិដ្ឋកម្មនេះ។

---

[25] M. Cherif Bassiouni "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" អាចរកបាននៅគេហទំព័រ៖ www.crimesofwar.org/a-z-guide/crimes-against-humanity/#sthash.aOwRmBrM.dpuf

[26] Luban, កំណត់សម្គាល់ ២៤, លេខ ១០១, ជើងទំព័រ ៥៩។

[27] Hansdeep Singh (ឆ្នាំ ២០០៩)។ "ការរិះគន់លើសាលដីការបស់អង្គជំនុំជម្រះសាលាដំបូង លើរឿងក្តី Mrkšc (ICTY)៖ ការវាយតម្លៃឡើងវិញ ថាតើទាហានដែលបាត់បង់សមត្ថភាពប្រយុទ្ធ មានសិទ្ធិទទួលបានការទទួលស្គាល់ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬទេ" *ច្បាប់ និងការអនុវត្តនៃតុលាការអន្តរជាតិ* ៨, ២៤៧ ដល់ ២៨១។

[28] សូមមើល រឿងក្តី *Kupreškic និងអ្នកផ្សេងទៀត*, កំណត់សម្គាល់ ២១, កថាខណ្ឌ ៥៤៧ ដល់ ៥៤៩; រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Jelisic* (IT9510T), ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩, កថាខណ្ឌ ៥៤។